# GST និងម្ហូបអាហារ

## ការចាប់ផ្តើម

### តើពន្ធ GST ជាអ្វី?

ពន្ធដារលើទំនិញ និងសេវា (GST) គឺជាពន្ធដារចំនួន 10% លើទំនិញ និងសេវាភាគច្រើនដែលលក់ ឬប្រើប្រាស់ក្នុងប្រទេសអូស្ត្រាលី។ ប្រសិនបើលោកអ្នកប្រកបពាណិជ្ជកម្ម លោកអ្នកចាំបាច់ត្រូវដឹងអំពីពន្ធ GST។

នៅពេលអាជីវកម្មរបស់លោកអ្នកចុះបញ្ជីពន្ធ GST លោកអ្នកត្រូវ:

- ដាក់បញ្ចូលពន្ធ GST ទៅក្នុងតម្លៃលក់ទៅឲ្យអតិថិជនរបស់លោកអ្នកហើយ
- ទាមទារយកឥណទានពន្ធ GST (GST Credits) ដែលនៅក្នុងតម្លៃដែលលោកអ្នកបានទិញសំរាប់អាជីវកម្មរបស់លោកអ្នក។

> ដើម្បីរកពត៌មានថែមទៀតអំពីពន្ធ GST និងរបៀបចុះឈ្មោះអាជីវកម្មរបស់លោកអ្នក:
> - សូមបើកមើលវិបសាយរបស់ក្រសួងយើងនៅត្រង់ **www.ato.gov.au/gst**
> - សូមមើលកូនសៀវភៅតូចៗដូចតទៅនេះ (ជាភាសាអង់គ្លេស) ដែលអាចទទួលយកបាននៅតាមអ៊ីនធើណិត
>   - *GST សំរាប់ពាណិជ្ជកម្មតូចតាច (GST for small business)* (NAT 3014) ជាភាសាអង់គ្លេស
>   - *ពន្ធដារជាមូលដ្ឋានសំរាប់ពាណិជ្ជកម្មតូចតាច (Tax basics for small businesses)* (NAT 1908) ជាភាសាអង់គ្លេស
>   - *GST* (NAT 72420) មានជាភាសាដទៃទៀត
> - ទូរស័ព្ទទៅ ATO តាមលេខ **13 28 66**
> - ពិភាក្សាជាមួយទីប្រឹក្សាផ្នែកពន្ធដាររបស់លោកអ្នក។

## GST និងម្ហូបអាហារ

ម្ហូបអាហារទាំងអស់ដែលគេលក់មិនមែនសុទ្ធតែទាក់ទិននឹងពន្ធ GST នោះទេ។ ប្រសិនបើលោកអ្នកលក់ម្ហូបអាហារក្នុងអាជីវកម្មរបស់លោកអ្នក លោកអ្នកចាំបាច់ត្រូវដឹងថាតើទំនិញមួយណាដែលត្រូវគិតពន្ធ GST។ ជាទូទៅ លោកអ្នកត្រូវដាក់បញ្ចូលពន្ធ GST ទៅក្នុងតម្លៃទំនិញ និងសេវាដែលលោកអ្នកលក់ ឬផ្តល់។ ការទាំងនេះហៅថា ‘ការលក់ដែលអាចគិតពន្ធ’ (taxable sales)។

មានទំនិញ និងសេវាមួយចំនួនដែល ‘ឥតមានពន្ធ GST’ (GST-free) មានន័យថា លោកអ្នកពុំត្រូវគិតពន្ធ GST ពីអតិថិជនរបស់លោកអ្នកឡើយ ហើយលោកអ្នកក៏ពុំត្រូវបង់ពន្ធ GST ទៅឲ្យ ATO ដែរ។ ម្ហូបអាហារចាំបាច់ភាគច្រើន ‘ឥតមានពន្ធ GST’ ឡើយ។

### ឧទាហរណ៍នៃម្ហូបអាហារដែល ‘ឥតមានពន្ធ GST’ មានជាអាទិ:

- នំប៉័ង និងនំប៉័ងមូលដែលគ្មានដាក់ស្ករលាបនំ ឬស្នូល
- គ្រឿងផ្សំសំរាប់ធ្វើម្ហូប ដូចជាម្សៅ ស្ករ គ្រឿងលាយធ្វើនំជាដើម
- ខ្លាញ់ និងប្រេងសំរាប់ចំអិនអាហារ
- ទឹកដោះគោ ក្រែម ឈីស និងស៊ុត
- គ្រឿងទេស និងទឹកជ្រលក់
- ទឹកផ្លែឈើដែលយ៉ាងហោចណាស់មាន 90% នៃចំណុះទឹកផ្លែឈើ
- ទឹកផឹកក្នុងដប
- តែ និងកាហ្វេ (លើកលែងតែវាឆុងរួចស្រេចសំរាប់ផឹក)
- អាហារសំរាប់ទារក និងម្សៅទឹកដោះសំរាប់ទារក
- សាច់សត្វសំរាប់មនុស្សបរិភោគ (លើកលែងតែជាអាហារ ឬអាហារសម្រន់ដែលគេធ្វើរួចស្រេច)
- ផ្លែឈើ បន្លែ ត្រី និងសម្លស៊ុប
- ទឹកដមខាប់ ដូចជាទឹកឃ្មុំ ដំណាប់ផ្លែឈើ និងប័រសណ្តែកដី
- គ្រាប់ធញ្ញជាតិធ្វើជាអាហារពេលព្រឹក
- បាយឆ្អិន (ដែលពុំនៅក្តៅ) ឬអង្ករ។

> ថ្វីដ្បិតតែទំនិញរបស់លោកអ្នកអាចនៅក្នុងបញ្ជីម្ហូបអាហារដែល ‘ឥតមានពន្ធ GST’ ក៏ដោយ វាក៏នៅតែអាចគិតពន្ធក្នុងកាលៈទេសៈមួយចំនួនដែរ។ ឧទាហរណ៍ នំប៉័ងមូល ‘ឥតមានពន្ធ GST’ ឡើយ លើកលែងតែលោកអ្នកលក់វានៅក្នុងភោជនីយដ្ឋានដែលភ្ញៀវរបស់លោកអ្នកនឹងបរិភោគវានៅក្នុងភោជនីយដ្ឋាននោះ។ ចំពោះពត៌មានបន្ថែម សូមមើល‘កន្លែងដែលលក់ ឬបរិភោគម្ហូបអាហារអាចធ្វើឲ្យប៉ះពាល់ពន្ធ GST’ នៅទំព័រ 3។



Australian Government
Australian Taxation Office

### ឧទាហរណ៍នៃ ‘ម្ហូបអាហារដែលអាចគិតពន្ធ’ មានជាអាទិ:

- ផលិតផលនំដុត ដូចជានំ (cakes), នំម្សៅ (pastries) និងនំផាយ (pies)
- នំប៊ីស្គីត (biscuits), នំរាងសាជី (cones) និងនំម្យ៉ាងតូចស្តើង (wafers)
- អាហារសម្រន់ដែលមានដាក់រសជាតិ ដូចជាចំណិតដំឡូងបារាំងចៀនក្រៀម
- សូកូឡា និងស្ករគ្រាប់
- ការ៉េមកី
- ភេសជ្ជៈមានជាតិផ្អែម និងទឹកដោះគោដែលមានដាក់រសជាតិ ដូចជាទឹកដោះគោសូកូឡាជាដើម
- ម្ហូបអាហាររៀបដាក់ក្នុងចានសំប៉ែត (food platters)
- អាហារលក់ក្នុងទីផ្សារជាអាហាររៀបចំរួចស្រេចដូចជា sushi សម្លការី និងអាហារដែលមានលាយបាយ
- អាហារទាំងឡាយណាដែលពុំមែនសំរាប់មនុស្សបរិភោគ ដូចជាអាហារសំរាប់សត្វចិញ្ចឹមជាដើម
- ម្ហូបអាហារ និងភេសជ្ជៈ**ទាំងអស់**ដែលលក់ក្នុងភោជនីយដ្ឋាន ឬសំរាប់បរិភោគនៅនឹងកន្លែង - ចំពោះពត៌មានបន្ថែម សូមមើល ‘កន្លែងដែលលក់ ឬបរិភោគម្ហូបអាហារដែលធ្វើឲ្យប៉ះពាល់ពន្ធ GST’ នៅទំព័រ 3។

មានទំនិញខ្លះដែលពុំបានចាត់ទុកជាម្ហូបអាហារឡើយ ដោយព្រោះថាលោកអ្នកពុំទាន់អាចបរិភោគវាបាននៅឡើយ។ ទំនិញទាំងនេះ “អាចគិតពន្ធ” (taxable) ហើយរួមមាន:

- សត្វនៅរស់
- រុក្ខជាតិ និងគ្រាប់ពូជដែលសំរាប់ដាំបណ្តុះទៅជាផ្លែឈើនិងបន្លែ។

> ប្រសិនបើលោកអ្នកពុំដឹងប្រាកដថាតើម្ហូបអាហាររបស់លោកអ្នកអាចគិតពន្ធ ឬពុំគិតពន្ធ GST នោះលោកអ្នកអាចឆែកមើលជាមួយ ATO ជានិច្ចដោយ:
>
> - បើកមើលវ៉ិបសាយរបស់ក្រសួងយើងនៅត្រង់ **www.ato.gov.au/foodindustry** បន្ទាប់មកជ្រើសយក ‘Basic topics’, ‘Publications’ និង ‘Detailed food list’– បញ្ជីម្ហូបអាហារនេះប្រាប់ឲ្យដឹងអំពីស្ថានភាពពន្ធ GST នៃម្ហូបអាហារចំនួនច្រើនជាង 500 មុខ
> - សូមមើលកូនសៀវភៅតូចៗអំពី *សេចក្តីណែនាំអំពីពន្ធ* GST *លើម្ហូបអាហារ* (GST food guide) (NAT 3338) (ជាភាសាអង់គ្លេស) ដែលអាចទទួលយកបាននៅតាមអ៊ីនធើណិត
> - ទូរស័ព្ទទៅ ATO តាមលេខ **13 28 66**
> - ពិភាក្សាជាមួយទីប្រឹក្សាផ្នែកពន្ធដាររបស់លោកអ្នក។

### ពន្ធ **GST** និងប្រព័ន្ធទំនាក់ទំនងគ្នាសំរាប់ការផ្គត់ផ្គង់ម្ហូបអាហារ

ពន្ធ GST ត្រូវបានអនុវត្តនៅដំណាក់កាលជាក់លាក់ក្នុងប្រព័ន្ធទំនាក់ទំនងគ្នាសំរាប់ការផ្គត់ផ្គង់ម្ហូបអាហារ។ ប្រសិនបើ លោកអ្នកមានអាជីវកម្មដែលបានចុះឈ្មោះសំរាប់ពន្ធ GST លោកអ្នកអាចទាមទារយកឥណទានពន្ធ GST (GST credits) សំរាប់ពន្ធ GST ដែលលោកអ្នកបានបង់នៅក្នុងតម្លៃទំនិញម្ហូបអាហារដែលលោកអ្នកបានទិញសំរាប់ពាណិជ្ជកម្មរបស់លោកអ្នក។

> លោកអ្នកពុំអាចទាមទារយកឥណទានពន្ធ GST សំរាប់ម្ហូបអាហារដែលលោកអ្នកបានចំណាយសំរាប់ការកំសាន្ត (entertainment expenses) ឡើយ ប្រសិនបើលោកអ្នកពុំអាចទាមទារការកាត់បន្ថយពន្ធដារលើប្រាក់ចំណូល (income tax deduction) ចំពោះការចំណាយនេះ។

### ឧទាហរណ៍: តើនៅពេលណាទើបពន្ធ **GST** ត្រូវបានគិតចូលនៅក្នុងប្រព័ន្ធទំនាក់ទំនងគ្នាសំរាប់ការផ្គត់ផ្គង់ម្ហូបអាហារ?

> កន្លែងបណ្តុះ និងលក់ដើមឈើមួយកន្លែង បានលក់គ្រាប់សាឡាត់ទៅឲ្យអ្នកចំការម្នាក់។ គ្រាប់សាឡាត់គឺត្រូវគិតពន្ធ ព្រោះវាជារុក្ខជាតិសំរាប់ដាំបណ្តុះ ហើយគេពុំទាន់អាចបរិភោគវាបាននៅឡើយ។ កន្លែងបណ្តុះនិងលក់ដើមឈើគិតពន្ធ GST ពីអ្នកចំការ ហើយបង់ពន្ធនេះទៅឲ្យ ATO។
>
> អ្នកចំការអាចទាមទារយកឥណទានពន្ធ GST សំរាប់ពន្ធ GST ដែលគេបានបង់នៅក្នុងតម្លៃទិញគ្រាប់សាឡាត់នោះ។
>
> អ្នកចំការដាំបណ្តុះសាឡាត់ ហើយលក់វាទៅឲ្យអ្នកលក់បន្លែបោះដុំដោយពុំគិតពន្ធ GST ឡើយ។ សាឡាត់នោះជាបន្លែ ឥតមានពន្ធ GST ទេ ដោយព្រោះថាឥឡូវនេះវាជាអាហារសំរាប់មនុស្សបរិភោគ។
>
> អ្នកលក់បន្លែបោះដុំ លក់សាឡាត់នោះដោយឥតមានពន្ធ GST ទៅឲ្យទីផ្សារធំ។
>
> នៅទីផ្សារធំ មនុស្សទាំងឡាយទិញសាឡាត់ដោយឥតមានពន្ធ GST។

## កន្លែងដែលលក់ ឬបរិភោគម្ហូបអាហារអាចធ្វើឲ្យប៉ះពាល់ពន្ធ GST

ម្ហូបអាហារ និងភេសជ្ជៈទាំងអស់ ដែលគេលក់ក្នុងភោជនីយដ្ឋានដើម្បីឲ្យគេបរិភោគ ឬផឹកនៅកន្លែងដែលគេលក់ សុទ្ធតែត្រូវបង់ពន្ធ ទោះបីវាជាទំនិញ 'ឥតមានពន្ធ GST' ក៏ដោយ។

ការនេះមានន័យថាលោកអ្នកត្រូវគិតពន្ធ GST ពីអតិថិជនរបស់លោកអ្នក ហើយបង់ពន្ធ GST នោះទៅឲ្យ ATO ប្រសិនបើលោកអ្នកលក់ម្ហូបអាហារនិងភេសជ្ជៈនៅ:

- ភោជនីយដ្ឋាន ឬហាងកាហ្វេ
- ហាង ឬតូបលក់អាហារសម្រន់តូចតាច
- ទីកន្លែងគ្នាណាមួយដែលទាក់ទិននឹងការលំហែ កីឡា ឬការកំសាន្ត ដូចជា
  - ទីធ្លាលេងកីឡា
  - កន្លែងលេងវាយកូនគោល
  - កន្លែងហាត់កាយសម្ព័ន្ធ
  - វាលវង់ប្រណាំងសេះ
  - រោងល្ខោន
  - សារមន្ទីរ
  - កន្លែងតាំងវត្ថុសិល្បៈ
  - រោងភាពយន្ត
  - ទីធ្លាមានលេងល្បែងកំសាន្តផ្សេងៗ។

> ក្នុងករណីមួយចំនួន អង្គការសប្បុរសធម៌ មូលនិធិសប្បុរសធម៌ មូលនិធិ ឬអង្គភាពទទួលអំណោយដែលអាចយកទៅទាមទារកាត់ពន្ធដារបាននិងសាលារៀនរដ្ឋ (ឧទាហរណ៍ កន្លែងលក់ម្ហូបអាហារសំរាប់សិស្ស) ដែលលក់ម្ហូបអាហារសំរាប់ការប្រមូលជំនួយសប្បុរសធម៌ ឬសំរាប់គោលបំណងប្រហែលគ្នានេះ គេពុំគិតពន្ធ GST ទេ។

> បើកមើល **www.ato.gov.au/nonprofit** ឬឆែកមើលជាមួយ ATO តាមទូរស័ព្ទលេខ **13 28 66** ប្រសិនបើលោកអ្នកពុំដឹងច្បាស់ប្រាកដ។

### ឧទាហរណ៍

**ហាងលក់នំរបស់នាងរ៉ាវី**

នាងរ៉ាវីលក់នំប័ុង និងនំប័ុងមូលធម្មតានៅហាងលក់នំរបស់នាង។ នំប័ុងទាំងនេះពុំមានដាក់ស្ករ ឬស្រូលីឡើយ។ នាងលក់នំប័ុងឲ្យអតិថិជនរបស់នាងសំរាប់ឲ្យគេបរិភោគនៅកន្លែងឯទៃក្រៅអំពីនៅក្នុងហាងរបស់នាង។

នាងពុំគិតពន្ធ GST ពីអតិថិជនរបស់នាងឡើយ។

**ភោជនីយដ្ឋានរបស់នាងចិន្តា**

នាងចិន្តាលក់នំប័ុងមូលធម្មតានៅភោជនីយដ្ឋានរបស់នាង។ អាហារទាំងនេះត្រូវបានរៀបចំសំរាប់ការបំរើម្ហូបនៅក្នុងភោជនីយដ្ឋាននិងសំរាប់ឲ្យគេបរិភោគនៅក្នុងភោជនីយដ្ឋាន។

នាងចិន្តាគិតពន្ធ GST ពីអតិថិជនរបស់នាង ហើយបង់ពន្ធ GST នេះទៅឲ្យ ATO។

**រថយន្តលក់កាហ្វេរបស់បូណា**

បូណាប្រកបអាជីវកម្មលក់កាហ្វេចល័ត។ គាត់បើកបរឡានរបស់គាត់ទៅកន្លែងផ្សេងៗដែលមានមហោស្រព ឬព្រឹត្តិការណ៍សំខាន់ៗ។ គាត់លក់ភេសជ្ជៈក្តៅៗដូចជាកាហ្វេ និងសូកូឡាក្តៅ។ គាត់ក៏លក់ទឹកដបផងដែរ។ ភេសជ្ជៈក្តៅអាចគិតពន្ធបានដោយព្រោះថាទំនិញទាំងនេះត្រូវបានចាត់ទុកជា 'ភេសជ្ជៈរៀបចំរួចស្រេចសំរាប់ផឹក'។ ទឹកដបក៏អាចគិតពន្ធបានដែរ ដោយព្រោះថាបូណាលក់ឲ្យអតិថិជនសំរាប់ឲ្យគេផឹកវានៅកន្លែងដែលមានព្រឹត្តិការណ៍។

បូណាគិតពន្ធ GST ពីអតិថិជនរបស់គាត់ ហើយគាត់បង់ពន្ធ GST នេះទៅឲ្យ ATO។

**ហាងលក់ទឹកផ្លែឈើរបស់នាងចាន់ណារី**

នាងចាន់ណារីមានហាងលក់ទឹកផ្លែឈើតូចមួយនៅទីធ្លាលក់ម្ហូបអាហារចម្រុះ។ នាងលក់ទឹកផ្លែឈើ100% ទឹកផ្លែឈើក្រឡុកលាយគ្នានិងទឹកដប ទំនិញទាំងអស់នេះអាចគិតពន្ធបានដោយព្រោះថាវាសំរាប់ផឹកនៅទីធ្លាលក់ម្ហូបអាហារចម្រុះ។

នាង ចាន់ណារី គិតពន្ធ GST ពីអតិថិជនរបស់នាង ហើយបង់ពន្ធ GST នេះទៅឲ្យ ATO។

## ពត៌មានបន្ថែម

ចំពោះពត៌មានបន្ថែម:

- បើកមើលវ៉ិបសាយរបស់យើងនៅត្រង់
  - **www.ato.gov.au/gst**
  - **www.ato.gov.au/foodindustry**
  - **www.ato.gov.au/otherlanguages** ចំពោះពន្ធដារនិងប្រាក់សោធនសំរាប់ពេលចូលនិវត្តន៍ មានពត៌មានជា25 ភាសា។ លោកអ្នកក៏អាចមើល ឬទាញយកវីឌីអូ អំពីអាជីវកម្មរបស់លោកអ្នកនិងពន្ធដារ *(Your Business and Tax)* ដែលពន្យល់អំពីអ្វីដែលលោកអ្នកត្រូវការដឹងអំពីប្រព័ន្ធពន្ធដារអាជីវកម្មរបស់អូស្ត្រាលី។ ពត៌មាននេះមានផ្តល់ជូនជាប្រាំមួយភាសា មានរួមទាំងភាសាអង់គ្លេសផងដែរ។
- ទូរស័ព្ទ infoline អំពីពន្ធដារអាជីវកម្មរបស់ ATO តាមលេខ **13 28 66** រវាងម៉ោង8.00ព្រឹក និងម៉ោង6.00ល្ងាច ថ្ងៃច័ន្ទទៅថ្ងៃសុក្រ ពេលម៉ោងតំបន់ខាងកើត (EST)
- ទៅមើលកន្លែងទទួលភ្ញៀវ (shopfront) របស់ក្រសួងយើង
- ពិគ្រោះជាមួយទីប្រឹក្សាផ្នែកពន្ធដាររបស់លោកអ្នក។

ប្រសិនបើលោកអ្នកថ្លង់ ឬមានពិការភាពក្នុងការស្តាប់ ឬការនិយាយស្តី សូមទូរស័ព្ទមកយើងតាមរយៈកិច្ចបំរើជាតិបញ្ជូនតគ្នា (NRS) តាមលេខ ដូចមានចុះខាងក្រោម:

- ចំពោះអ្នកប្រើប្រាស់ TTY សូមទូរស័ព្ទលេខ **13 36 77** ហើយសួររកលេខទូរស័ព្ទរបស់ ATO ដែលលោកអ្នកត្រូវការ (Speech-to-Speech relay)
- ចំពោះអ្នកប្រើប្រាស់កិច្ចបំរើសំរាប់អ្នកមានពិការភាពខាងការនិយាយស្តី សូមទូរស័ព្ទលេខ**1300 555 727** ហើយសួររកលេខទូរស័ព្ទរបស់ ATO ដែលលោកអ្នកត្រូវការ។
- ចំពោះអ្នកប្រើប្រាស់អ៊ីនធើណិតបញ្ជូនតគ្នា សូមតភ្ជាប់ទៅ NRS តាមវ៉ិបសាយ **www.relayservice.com.au** ហើយសួររកលេខទូរស័ព្ទរបស់ ATO ដែលលោកអ្នកត្រូវការ។

## សូមតាមដានជាមួយយើង:

- **www.twitter.com/ato_gov_au**
- **www.facebook.com/ato.gov.au**
- **www.youtube.com/AusTaxOffice**

## ការប្តេជ្ញាចិត្តរបស់យើងចំពោះលោកអ្នក

យើងប្តេជ្ញាចិត្តផ្តល់ជូនលោកអ្នកនូវពត៌មានដែលត្រឹមត្រូវសមស្របគ្នា ហើយច្បាស់លាស់ដើម្បីជួយលោកអ្នកឲ្យយល់ដឹងអំពីសិទ្ធិនឹងសិទ្ធិទទួលនិងដើម្បីបំពេញកាតព្វកិច្ចនានារបស់លោកអ្នក។

ប្រសិនបើលោកអ្នកយល់ថាការបោះពុម្ពផ្សាយនេះមិនត្រូវនឹងកាលៈទេសៈរបស់លោកអ្នកទាំងស្រុងទេនោះ ឬលោកអ្នកមិនប្រាកដថាតើគេអនុវត្តយ៉ាងណាចំពោះលោកអ្នកនោះ លោកអ្នកអាចស្នើសុំជំនួយបន្ថែមទៀតពីយើង។

យើងធ្វើការកែតម្រូវការបោះពុម្ពផ្សាយនានារបស់យើងជាទៀងទាត់ដើម្បីបង្ហាញឲ្យឃើញនូវការកែប្រែច្បាប់ទាំងឡាយ ដូច្នេះសូមលោកអ្នកធ្វើឲ្យប្រាកដថាពត៌មានដែលលោកអ្នកប្រើជាពត៌មានថ្មីចុងក្រោយបំផុត។ ប្រសិនបើលោកអ្នកមិនច្បាស់ លោកអ្នកអាចរកបានពត៌មានថ្មីៗនៅក្នុងវ៉ិបសៃរបស់យើងគឺ **www.ato.gov.au** ឬទាក់ទងយើងដោយផ្ទាល់។

ការបោះពុម្ពផ្សាយនេះត្រឹមត្រូវនៅ**ខែមិថុនា ឆ្នាំ 2012**។

**© AUSTRALIAN TAXATION OFFICE**
**សំរាប់សហព័ន្ធអូស្ត្រាលី ឆ្នាំ 2012**

លោកអ្នកអាចចម្លងយកលំនាំតាម កែប្រែ បញ្ជូនត ហើយចែកចាយសម្ភារៈផ្សព្វផ្សាយនេះបានដោយសេរីទៅតាមការប្រាថ្នារបស់រលោកអ្នក (ក៏ប៉ុន្តែសម្ភារៈផ្សព្វផ្សាយនេះ មិនមែនផ្តល់យោបល់ថាក្រសួង ATO ឬសហព័ន្ធផ្តល់ការគាំទ្រលោកអ្នក ឬសេវាណាមួយរបស់លោកអ្នកនោះឡើយ)។

**បោះពុម្ពផ្សាយដោយ**

Australian Taxation Office
Canberra
ខមិថុនា 2012

JS 24698